ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 12-Jan-2015, 14:02
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧/អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007/ECCC/SC

**នៅចំពោះមុខ៖**

ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម **Chandra Nihal JAYASINGHE**
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម **Agniezska KLONOWIECKAMILART**
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម **Florence Ndepele Mwachande MUMBA**
ចៅក្រម យ៉ា ណារិន

**កាលបរិច្ឆេទឯកសារ៖** ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៥
**ភាសាដើម៖** ខ្មែរ/អង់គ្លេស/បារាំង
**ចំណាត់ថ្នាក់ឯកសារ៖** សាធារណៈ

---

# សេចក្តីសម្រេចលើសំណើរបស់ នួន ជា សុំដាក់សារណាបន្ថែមទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១

---

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ
Victor KOPPE

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Marie GUIRAUD

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

Arthur VERCKEN

**អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”)៖

**បានទទួល** បណ្តឹងសាទុក្ខ[1] ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ (“សាលក្រម”);[2]

**បានទទួល** សំណើរបស់មេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) ដែលបានដាក់នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០១៤ ស្នើសុំការអនុញ្ញាតដាក់សារណាបន្ថែមលើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម (“សំណើសុំ”)[3],

**កត់សម្គាល់**ថា មេធាវីការពារក្តី បង្ហាញពីចេតនារបស់ខ្លួនក្នុងការបន្ថែមទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសារណាបណ្តឹងសាទុក្ខ ទាក់ទងនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពិសេស“លើសំណើសុំប្តឹងជំទាស់ចៅក្រមអង្គជំនុំជម្រះសាលាដំបូង”[4] ដោយរួមបញ្ចូលនូវមតិជំទាស់របស់ចៅក្រម Rowan Downing[5] ដែលសំអាងហេតុ ពុំទាន់ត្រូវបានជូនដំណឹងនៅឡើយ,

**រំលឹកថា** សេចក្តីសម្រេចលើបណ្តឹងជំទាស់នេះបានបដិសេធចោលលើសំណើសុំដកចៅក្រមមួយចំនួន ឬទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូងចេញពីសំណុំរឿង ០០២/០២[6] រួមទាំង“ចេញពីនីតិវិធីណាមួយបន្ថែម

---

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង សាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ F11, ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ F16, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៤ (“សារណាបណ្តឹងសាទុក្ខរបស់ នួន ជា”); *[Corrigé 1] Mémoire d'appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01*, ឯកសារលេខ F17, ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៤។

[2] សំណុំរឿង ០០២/០១ សាលក្រម ឯកសារលេខ E313, ចុះថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤។

[3] សំណើរបស់ នួន ជា ស្នើសុំដាក់សារណាបន្ថែមលើបណ្តឹងសាទុក្ខរបស់ខ្លួនប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារលេខ F15។

[4] ឯកសារលេខ E314/12, ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ (“សេចក្តីសម្រេចលើបណ្តឹងជំទាស់”)។

[5] សេចក្តីសម្រេចលើបណ្តឹងជំទាស់ ទំព័រ ៣ និង ៤។

[6] *Demande de réexamen de M. KHIEU Samphân sur la nécessité d'attendre un jugement définitif dans le procès 002/01 avant de commencer le procès 002/02 et sur la nomination d'un nouveau collège de juges*, ឯកសារលេខ E314/1, ថ្ងៃទី ២៥ ខែសីហា ឆ្នាំ២០១៤, កថាខណ្ឌ ៥៤; សំណើសុំរបស់ នួន ជា ដកចៅក្រម និល ណុន, យ៉ា សុខន, Jean-Marc LAVERGNE, និងចៅក្រម យូ ឧត្តរា ឯកសារលេខ E314/6, ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៤ (“សំណើរបស់ នួន ជា សុំប្តឹងជំទាស់ចៅក្រម”), កថាខណ្ឌ ១៣៨។ *Requête réitérée en récusation des juges composant actuellement la*

ទៀតប្រឆាំងនឹងនួនជាផងដែរ”[7]។ ដោយឃើញថា សេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តនេះ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០២ ហើយមិនជាប់ពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ននេះទេ ដូច្នេះហើយ វាជាការសំខាន់និងដំបូងគេបង្អស់នៅក្នុងកិច្ចដំណើរការនីតិវិធីទាំងនោះ ដែលមេធាវីការពារក្តីត្រូវលើកសំណើរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះ។

**ដោយពិចារណាឃើញថា** មេធាវីការពារក្តី នៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ខ្លួន បានលើកឡើងនូវទឡ្ហីករណ៍ និងអំណះអំណាងមួយចំនួនរួចហើយពាក់ព័ន្ធនឹងបញ្ហាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[8] ហើយបើទោះបីជាបានអះអាងថា សំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងជំទាស់ចិត្តនេះ “មានលក្ខណៈសំខាន់ជាពិសេសសម្រាប់បណ្តឹងសាទុក្ខរបស់ខ្លួន”[9] យ៉ាងណាក៏ដោយ ក៏មេធាវីការពារក្តី ខកខានក្នុងការបង្ហាញភស្តុតាងអំពីទំនាក់ទំនង និង/ឬភាពជាប់ពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍នានានៃបណ្តឹងសាទុក្ខ ដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន។

**អាស្រ័យហេតុនេះ÷**

**សម្រេចបដិសេធ**សំណើនេះចោលជាអសារបង់។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

---

Chambre de première instance devant statuer sur le procès 002/02*, ឯកសារលេខ E314/8, ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៤ ទំព័រ ៦។

[7]សំណើរបស់ នួន ជា សុំប្តឹងជំទាស់ចិត្តចៅក្រម កថាខណ្ឌ ១៣៨។

[8] *សូមមើល ឧទាហរណ៍* សារណាបណ្តឹងសាទុករបស់នួន ជា កថាខណ្ឌ ៤០ដល់ ១១។

[9] សំណើសុំ, កថាខណ្ឌ ៤។